STATE OF CALIFORNIA—HEALTH AND HUMAN SERVICES AGENCY
**DEPARTMENT OF SOCIAL SERVICES**
744 P Street • Sacramento, CA 95814 • www.cdss.ca.gov

CDSS
**WILL LIGHTBOURNE**
DIRECTOR

**EDMUND G. BROWN JR.**
GOVERNOR

ជូនចំពោះបុគ្គលិកផ្តល់កិច្ចជួយធ្វើកិច្ចការក្នុងផ្ទះ (In-Home Supportive Services ឬ IHSS) :

ក្រសួងសង្គមកិច្ចនៃរដ្ឋកាលីហ្វ័រនីញ៉ា (California Department of Social Services ឬ CDSS) មានសេចក្តីរីករាយនឹងជំរាបលោកអ្នកថា ឥឡូវនេះសែកប្រាក់ខែសំរាប់បុគ្គលិកធ្វើការ IHSS អាចត្រូវបានដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) ទៅក្នុងធនាគាររបស់លោកអ្នក ។

*<u>តើការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) គឺជាអ្វី?</u>*

ការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) គឺជាការជ្រើសរើសមួយ ដើម្បីទទួលសែកប្រាក់ខែ IHSS របស់លោកអ្នក ។ តាមវិធីដាក់បញ្ចូលដោយផ្ទាល់នេះ សែកប្រាក់ខែ IHSS របស់លោកអ្នកត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងគណនីសែកឬសន្សំរបស់លោកអ្នក ជាជំនួសការផ្ញើសែកនេះទៅជូនលោកអ្នកតាមសំបុត្រ ។ សែកប្រាក់ខែរបស់លោកអ្នកអាចត្រូវបានដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នកក្នុងធនាគារ ឬធនាគារសន្សំនិងខ្ចីប្រាក់ ឬធនាគារសហជីព ។

ដើម្បីកត់ចំណាំអំពីការបង់ប្រាក់ឱ្យរបស់លោកអ្នក លោកអ្នកនឹងទទួលសេចក្តីជំរាបអំពីការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit Remittance Advice) ដែលដូចគ្នានិងមានបង្ហាញពត៌មានដូចជាសេចក្តីរាយការណ៍នៃប្រាក់រកបាន (Statement of Earnings) (កន្ទុយសែក) ដែលលោកអ្នកទទួលភ្ជាប់ជាមួយសែកប្រាក់ខែ IHSS ក្នុងពេលបច្ចុប្បន្នរបស់លោកអ្នក ។ ជាមួយកន្ទុយសែករបស់លោកអ្នក លោកអ្នកក៏ទទួលផងដែរនូវសន្លឹកពេលវេលាធ្វើការថ្មីសំរាប់កំឡុងពេលបង់ប្រាក់ខែនៅពេលខាងមុខ ។

បើសិនជាលោកអ្នកចង់បន្តទទួលសែកប្រាក់ខែរបស់លោកអ្នកតាមសំបុត្រ លោកអ្នកមិនបាច់បំពេញសំណៅដែលភ្ជាប់ទៅជាមួយនេះទេ ឬក៏ធ្វើសកម្មភាពអ្វីមួយឡើយ ។ ក៏ប៉ុន្តែ បើសិនជាលោកអ្នកចង់ឱ្យសែកប្រាក់ខែរបស់លោកអ្នកបញ្ចូលដោយផ្ទាល់ទៅក្នុងធនាគាររបស់លោកអ្នកតាមការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) លោកអ្នកនឹងត្រូវបំពេញសំណៅដែលដាក់ភ្ជាប់ទៅជាមួយនេះ និងផ្ញើមកវិញ "សំណៅចុះឈ្មោះ/កែប្រែ/លុបចោលសំរាប់បុគ្គលិកផ្តល់កិច្ចជួយធ្វើកិច្ចការក្នុងផ្ទះក្នុងការដាក់បញ្ចូលដោយផ្ទាល់" “In-Home Supportive Services Provider Direct Deposit Enrollment/Change/Cancellation Form” ។

*<u>តើអ្វីទៅគឺជាផលប្រយោជន៍នៃការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit)</u>*?

- ✔ សែកប្រាក់ខែរបស់លោកអ្នកមិនអាចបាត់បង់តាមការផ្ញើសំបុត្រ ឬត្រូវគេលួចពីប្រអប់សំបុត្រ កាបូប ឬហោប៉ៅរបស់លោកអ្នកឡើយ ។
- ✔ លោកអ្នកអាចប្រើប្រាស់ប្រាក់របស់លោកអ្នកបានឆាប់ជាង ពីព្រោះលោកអ្នកមិនបាច់នៅរង់ចាំសែកផ្ញើមកតាមសំបុត្រ ។

*<u>តើអ្នកណាអាចមានសិទ្ធិទទួលការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit)</u>*?

- ✔ បុគ្គលិកធ្វើការ IHSS គ្រប់រូបអាចមានសិទ្ធិទទួលការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) បើសិនជាពួកគេ :
  - មានគណនីសែក ឬសន្សំ
  - នៅក្នុងពេលបច្ចុប្បន្ននេះទទួលសែកក្រដាសក្នុងមួយខែពីរដង និង
  - បានធ្វើការឱ្យកម្មវិធី IHSS សំរាប់ពេលយ៉ាងតិចណាស់៩០ថ្ងៃ ។
  - មិនបានគ្រោងថានឹងផ្ញើប្រាក់១០០ភាគរយនៃប្រាក់ដែលដាក់បញ្ចូលក្នុងធនាគាររបស់លោកអ្នកនោះទៅធនាគារដទៃទៀតនៅក្រៅសហរដ្ឋអាមេរិក ។
- ✔ បើសិនជាអ្នកទទួលកិច្ចការនៃកម្មវិធី IHSS បង់ឱ្យលោកអ្នកដោយផ្ទាល់(ជាប្រាក់បង់ឱ្យមុន) លោកអ្នកមិនមានសិទ្ធិដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) នេះទេ ។
- ✔ ដើម្បីឱ្យលោកអ្នកបន្តភាពមានសិទ្ធិក្នុងការដាក់បញ្ចូលសែកដោយផ្ទាល់ (Direct Deposit) លោកអ្នកត្រូវផ្តល់មកនូវសន្លឹកពេលវេលាធ្វើការរបស់លោកអ្នកសំរាប់អ្នកទទួលកិច្ចការម្នាក់ៗដោយទាន់ពេល បន្ទាប់ពីពេលបញ្ចប់កំឡុងពេលបង់ប្រាក់នីមួយៗ ។

*<u>តើអ្វីកើតមានឡើង បើសិនជាខ្ញុំឈប់ធ្វើការឱ្យអ្នកទទួលកិច្ចការម្នាក់?</u>*

- ✔ អ្នកធ្វើការណាដែលឈប់ធ្វើការឱ្យអ្នកទទួលកិច្ចការនឹងត្រូវបានបង់ប្រាក់ឱ្យដោយប្រាក់ដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) បើសិនជាពួកគេផ្តល់សន្លឹកពេលវេលាធ្វើការរបស់គេនៅក្នុងពេល៦០ថ្ងៃនៃកំឡុងពេលបង់ប្រាក់ចុងក្រោយរបស់ពួកគេ ។ ***<u>បើសិនជាលោកអ្នកមិនផ្តល់សន្លឹកពេលវេលាធ្វើការណាសំរាប់ពេល៦០ថ្ងៃ ការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) របស់លោកអ្នកនឹងត្រូវបានលុបចោលដោយស្វ័យប្រវត្តិ ។</u>***
- ✔ ជាជំនួស លោកអ្នកនឹងទទួលសន្លឹកក្រដាសសែកតាមសំបុត្រសំរាប់សន្លឹកពេលវេលាធ្វើការណាដែលបានដាក់ស្នើបន្ទាប់ពីកំឡុងពេល៦០ថ្ងៃនេះ ។
- ✔ បើសិនជាលោកអ្នកត្រូវបានលុបចេញពីការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) ហើយលោកអ្នកចង់បានការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) ឡើងវិញ គេនឹងតម្រូវឱ្យលោកអ្នកចុះឈ្មោះសាឡើងវិញដោយការដាក់ពាក្យចុះឈ្មោះសាជាថ្មី ។

*តើខ្ញុំចុះឈ្មោះនៅក្នុងការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) តាមរបៀបណា?*

- ✔ ដើម្បីចុះឈ្មោះ លោកអ្នកត្រូវតែបំពេញសំណៅចុះឈ្មោះ/កែប្រែ/លុបចោលសំរាប់ការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit Enrollment/Change/Cancellation Form) ។ សូមធ្វើតាមការណែនាំដែលបានផ្ដល់ឱ្យនៅលើសំណៅនោះ ។
- ✔ ***សូមជ្រាបថា លោកអ្នកត្រូវបំពេញសំណៅចុះឈ្មោះផ្សេងពីគ្នា សំរាប់អ្នកទទួលកិច្ចការម្នាក់ៗ ដែលលោកអ្នកផ្ដល់កិច្ចការ IHSS*** ។ សំរាប់សំណៅបន្ថែម លោកអ្នកអាចចូលគេហទំព័រអ៊ិនធឺណិតរបស់យើងតាម www.dss.cahwnet.gov និងចុចលើផ្នែកមានចំណងជើង“Forms/Brochures” ដើម្បីចម្លងយកសំណៅចុះឈ្មោះនេះ ។ បើសិនជាលោកអ្នកចូលចិត្ត លោកអ្នកអាចទូរស័ព្ទទៅការិយាល័យជួយចំពោះអ្នកផ្ដល់កិច្ចការសំរាប់ការដាក់ប្រាក់បញ្ចូលដោយផ្ទាល់ (Provider Direct Deposit Help Desk) តាមលេខឥតបង់ប្រាក់ (866) 376-7066 និងសុំឱ្យគេផ្ញើសំណៅនោះមកជូនលោកអ្នក ។

*តើខ្ញុំត្រូវធ្វើយ៉ាងណាបើសិនជាខ្ញុំធ្វើការឱ្យអ្នកទទួលច្រើនជាងម្នាក់?*

- ✔ បើសិនជាលោកអ្នកធ្វើការឱ្យអ្នកទទួលជំនួយច្រើនជាងម្នាក់ ហើយចង់ដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) លោកអ្នកត្រូវតែបំពេញ និងដាក់ស្នើសំណៅចុះឈ្មោះសំរាប់អ្នកចុះឈ្មោះម្នាក់ៗដោយឡែកពីគ្នាសំរាប់អ្នកណាដែលលោកអ្នកធ្វើការជូន និងចង់ឱ្យប្រាក់ខែរបស់លោកអ្នកដាក់បញ្ចូលដោយផ្ទាល់ ។

*ពត៌មានបន្ថែមសំរាប់ការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit)*

- ✔ ការចុះឈ្មោះដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) ទាំងអស់នឹងត្រូវបានកាន់កាប់ដោយការិយាល័យកណ្ដាលមួយ ។ ***សូមកុំទូរស័ព្ទទៅការិយាល័យខណ្ឌរបស់លោកអ្នកដោយសារតែពួកគេមិនអាចជួយលោកអ្នកលើដំណើរការដាក់បញ្ចូលប្រាក់ដោយផ្ទាល់នេះបានទេ*** ។
- ✔ បើសិនជាលោកអ្នកមានសំណួរបន្ថែម ឬបញ្ហាណាមួយបន្ទាប់ពីនិយាយជាមួយធនាគាររបស់លោកអ្នក លោកអ្នកអាចទាក់ទងទៅការិយាល័យជួយចំពោះអ្នកផ្ដល់កិច្ចការសំរាប់ការដាក់ប្រាក់បញ្ចូលដោយផ្ទាល់ (Provider Direct Deposit Help Desk) តាមលេខឥតបង់ប្រាក់ (866) 376-7066 ។ ការិយាល័យជួយចំពោះអ្នកផ្ដល់កិច្ចការសំរាប់ការដាក់ប្រាក់បញ្ចូលដោយផ្ទាល់អាចផ្ញើសំណៅបន្ថែមជូនលោកអ្នក និងជួយបំពេញសំណៅរបស់លោកអ្នក ។
- ✔ នៅពេលដែលលោកអ្នកទូរស័ព្ទទៅការិយាល័យជួយចំពោះអ្នកផ្ដល់កិច្ចការសំរាប់ការដាក់ប្រាក់បញ្ចូលដោយផ្ទាល់ (Provider Direct Deposit Help Desk) លោកអ្នកត្រូវមានសេចក្ដីថ្លែងការប្រាក់រកបាន(កន្ទុយសែក)នៃកម្មវិធី IHSS របស់លោកអ្នក ឬឯកសារដទៃទៀតនៅពីមុខរបស់លោកអ្នកដែលមានបង្ហាញអំពីឈ្មោះ និងលេខសំណុំរឿងសំរាប់អ្នកទទួលម្នាក់ៗដែលលោកអ្នកទូរស័ព្ទសាកសួរ ។ លោកអ្នកត្រូវមានពត៌មាននេះដើម្បីអាចឱ្យការិយាល័យជួយចំពោះលោកអ្នកបាន ។

*នៅពេលណាដែលខ្ញុំសង្ឃឹមថាចំនួនប្រាក់ដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) ដំបូងត្រូវបានបង្ហាញចំនួននៅក្នុងគណនីធនាគាររបស់ខ្ញុំ?*

- ✔ លោកអ្នកនឹងបន្តទទួលក្រដាសសែកតាមប៉ុស្ដិ៍សំបុត្ររហូតទាល់តែគណនីដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit) ត្រូវបានបង្កើតឡើង ។
- ✔ វាអាចត្រូវចំណាយពេលរហូតដល់ទៅ៦០ថ្ងៃចាប់តាំងពីថ្ងៃដែលលោកអ្នកផ្ញើសំណៅចុះឈ្មោះរបស់លោកអ្នក រហូតទាល់តែប្រាក់ដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit) ដំបូងរបស់លោកអ្នកត្រូវបានធ្វើឡើង ។

*តើអ្វីនឹងកើតមានឡើងបើសិនជាខ្ញុំបិទឬផ្លាស់ប្ដូរគណនីធនាគាររបស់ខ្ញុំ?*

- ✔ សូមប្រាប់មណ្ឌលចាត់ចែងលើការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit Processing Center) តាមលេខឥតបង់ប្រាក់ (866) 376-7066 ជាបន្ទាន់ បើសិនជាលោកអ្នកផ្លាស់ប្ដូរលេខគណនីឬធនាគាររបស់លោកអ្នក ។ លោកអ្នកនឹងត្រូវបំពេញនិងចុះហត្ថលេខាលើសំណៅចុះឈ្មោះ/កែប្រែ/លុបចោលនៃការដាក់បញ្ចូលដោយផ្ទាល់ (Direct Deposit Enrollment/Change/Cancellation Form) ថ្មីមួយ ។ មណ្ឌលចាត់ចែងលើការដាក់បញ្ចូលប្រាក់ដោយផ្ទាល់ (Direct Deposit Processing Center) អាចផ្ញើសំណៅចុះឈ្មោះថ្មីមួយទៅជូនលោកអ្នក ឬលោកអ្នកអាចចូលទៅយកពីគេហទំព័រអ៊ិនធឺណិតដូចបានបង្ហាញនៅខាងលើ ។ សូមផ្ដល់សំណៅដែលបានបំពេញរួចមកមណ្ឌលចាត់ចែងលើការចុះឈ្មោះសំរាប់អ្នកធ្វើការ (Provider Enrollment Processing Center) អសយដ្ឋាន P. O. Box 1120, Roseville, CA 95678 ។
- ✔ ***សូមកុំអាលបិទគណនីចាស់របស់លោកអ្នក រហូតទាល់តែពេលលោកអ្នកទទួលប្រាក់បង់ឱ្យទីមួយរបស់លោកអ្នកនៅក្នុងគណនីថ្មីរបស់លោកអ្នក*** ។